# ដើមព្រហូត

មានរុក្ខជាតិខ្លះដុះក្នុងធម្មជាតិ មនុស្សអាចទាញពណ៌យកមកប្រើបាន សម្រាប់ជ្រលក់អំបោះកប្បាស សរសៃសូត្រ ឱ្យជិតពណ៌ ដើម្បីត្បាញសំពត់ហូល ហូលពិតាន ឬ ក្រមាជាដើម។ ឃើញថាមានដើមឈើច្រើនសម្បុណ៌បែបគួរសម ល្មមអាចនឹងលើកជាប្រធានបទស្រាវជ្រាវមួយវែងឆ្ងាយបាន។ ឧទាហរណ៍ ពួកអ្នកនេសាទដែលប្រើសំណាញ់ ឬ មង សម្រាប់បង់ត្រី និងវាយទាក់ត្រី តែងយកឧបករណ៍នេសាទនេះ ដែលទើបទិញពីផ្សារ ទៅត្រាំទឹកជាមួយសំបកកណ្ដោល ឬសំបកស្មាច់ ដើម្បីឱ្យអំបោះជាប់មាំល្អ និងប្រែពណ៌ពីសស្គុសទៅជាស្រអាប់បន្តិច បំណងនឹងបន្លំភ្នែកត្រីក្នុងទឹក។ ផ្លែមក្លឿ ឬមាក់ក្លឿ ផ្ដល់ពណ៌ខ្មៅជ្រលក់សំពត់។ បើដើមត្រុំផង មនុស្សស្គាល់ជាទូទៅថា ប្រើជ្រលក់អំបោះ ឬសូត្រឱ្យបានពណ៌ខៀវ។ ក្នុងនោះក៏មានដើមឈើមួយឈ្មោះហៅថា ព្រហូត ជារុក្ខជាតិផ្ដល់ពណ៌ផងដែរ។ ខាងក្រោមនេះខ្ញុំនឹងបង្ហាញពីរបៀបជ្រលក់ពណ៌ព្រហូតតាមទំនៀមរបស់អ្នកស្រុក រួមជាមួយរូបភាពខ្លះៗផង។

ព្រហូតជារុក្ខជាតិព្រៃ តែងឃើញមានដុះតាមព្រៃភ្នំឯកឯង(រូបលេខ១) ប៉ុន្តែដោយកម្រឃើញមានដុះនៅក្នុងភូមិដែរ នេះប្រហែលគេយកមកដាំ។ ដើមនេះមានកម្ពស់ពី១០ម៉ែត្រទៅ១៥ម៉ែត្រ និងមានឈ្មោះជាឡាតាំងថា Garcinia Vilersiana។ ផ្លែព្រហូតមានរូបរាង និងរសជូរ ដែលនាំឱ្យនឹកឃើញទៅដល់ផ្លែមង្ឃុត ហើយអាចហូបបានពេលទុំ។ ផ្នែកខ្លះទៀតរបស់ដើមប្រហូត គេអាចប្រើប្រាស់ជាឱសថព្យាបាលហ្វោះគ្រេចដៃជើង និងប្រើផ្កាជាគ្រឿងក្រអូបក្នុងពិធីផង (សូមមើល អ៊ឹម សុខរិទ្ធី, បណ្ដាញពត៌មានវប្បធម៌ខ្មែរ ជំពូក៥ លេខរៀង៤២)។ ផ្នែកដែលគេប្រើសម្រាប់ជ្រលក់ពណ៌គឺសំបក(រូបលេខ២)។ គេកាប់សកយកសំបកមកកាត់ជាដុំតូចៗ រួចដាក់ក្នុងឆ្នាំងដាំទឹកស្ងោរឱ្យពុះ ដើម្បីចេញពណ៌ពីជ័រសំបករបស់វា(រូបលេខ៣)។ ពណ៌ដែលចេញលឿងស្រអាប់។ គេត្រូវកូរដុំសាច់ជូរបង់បន្ថែម ដើម្បីឱ្យកាត់ពណ៌ឡើងជិតស្រស់ជាងមុនមួយកម្រិត។ បន្ទាប់មកយកសរសៃអំបោះកប្បាស ឬ សូត្រ ទៅជ្រលក់ក្នុងទឹកស្ងោរសំបកព្រហូត ដើម្បីបានជិតពណ៌ជាប់

អត្ថបទដោយៈ អាន រស្មី

(រូបលេខ២)។ គេត្រូវជ្រលក់ច្រើនដងផងដើម្បីឱ្យពណ៌ជ្រាបចូលសព្វសរសៃអំបោះ។ ពណ៌ដែលជិតជាប់ គេហៅពណ៌នេះថា ព្រហូត ដូច្នេះតែម្តង។ ជួនកាលបើ អ្នកជ្រលក់ចង់បានពណ៌ងាកទៅរកពណ៌ស្បង់លោកសង្ឃក្រហមស្រស់ គេត្រូវបង់គ្រាប់ជម្ពូ(រូបលេខ៥) ទៅក្នុងទឹកស្ងោរសំបកព្រហូត (តំបន់ខ្លះហៅថា គ្រាប់ម្នាក់ ឬផ្លែការី ឬក៏ជីកូរ)។ ពេលជ្រលក់ពណ៌ចូលសព្វអំបោះរួចហើយ គេយក សរសៃអំបោះ ឬសូត្រនោះទៅលាងទឹកសម្អាត។ បន្ទាប់មកហាលថ្ងៃឱ្យស្ងួត ដើម្បីទុកត្បាញលើកី(រូបលេខ៦-៧)។ នៅរូបលេខ៨ យើងឃើញកន្សែងពណ៌ព្រហូតទើបត្បាញរួច។

អ្នកនិពន្ធសម័យមុន ក៏បានលើកយករុក្ខជាតិព្រហូតមកតែងនិពន្ធក្នុងចម្រៀងដូចមានសម្រង់ថា កន្សែងសអើយកន្សែងសសូត្រ ជ្រលក់ព្រហូត រំយោលផ្កាក្តុម្ព។ ស្តាប់ទៅឮថា ដើមព្រហូតប្រើការសម្រាប់ជ្រលក់ពណ៌ដូច្នេះមែន។ បើក្រឡេកមើលឈ្មោះភូមិ និងវត្តខ្លះមានឈ្មោះព្រះហូត ដោយដាក់តាមដើមព្រហូត ដែលមានដុះក្នុងបរិស្ថានភូមិស្រុកទាំងនោះ (រូបលេខ៩)។ មកដល់ត្រង់នេះនាំឱ្យអ្នកអានអាចគិតថា រុក្ខជាតិនេះសំខាន់ក្នុងវប្បធម៌ និងចេញមុខមាត់ប៉ុណ្ណាក្នុងសង្គមខ្មែរ។


រូបលេខ១



រូបលេខ២

អត្ថបទដោយ៖ អាន រស្មី



រូបលេខ២៧៖ សំបកព្រហូតស្ងោរក្នុងឆ្នាំងលើភ្លើងដាំពុះ។ ពណ៌នៅក្នុងចានស្រាក់ដិត ស្រស់ជាងពណ៌ក្នុងឆ្នាំង ដោយសារគេបន្ថែមសាច់ជូរ មុននឹងចាក់ទៅក្នុងឆ្នាំង



រូបលេខ២៨



រូបលេខ២៩៖ ប្រភពរូប IKTT

អត្ថបទដោយ៖ អាន រស្មី



រូបលេខ៦៖ ហាលថ្ងៃអំបោះឱ្យស្ងួត ដើម្បីទុកត្បាញលើកី



រូបលេខ៧៖ ត្បាញអំបោះដែលស្ងួត

អត្ថបទដោយ៖ អាន ស្មើ



រូបលេខ២៨៖ កន្សែងពណ៌ព្រហូត



រូបលេខ២៩៖ ខ្លោងទ្វារវត្តសរសេរឈ្មោះថា វត្តព្រះហ៊ូត ខេត្តសៀមរាប

អត្ថបទដោយ៖ អាន រស្មី